**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ ២៨៣/១៦ សស.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈចលនាសហជីពនៃគណៈចលនាមហាជនគណៈកម្មាធិការកណ្តាល

**យោង** ៖- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលលេខ៣២៧/១៥សស.គក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល

- ស្មារតីអង្គប្រជុំរបស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច ៖**

**ប្រការ១** ៖ គណៈចលនាសហជីព អក្សរកាត់ "គ.ច.ស" មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជនក្នុងការដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំង យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារក្នុងស្រទាប់កម្មករនិយោជិត និងនិយោជក ដើម្បីធានាបាននូវសុខដុមនីយកម្មការងារចលនាកម្មករនិយោជិត ក្រោមការដឹកនាំរួមរបស់គណបក្ស។

**ប្រការ២** ៖ គណៈចលនាសហជីព មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកសាងផែនការរួម និងផែនការសកម្មភាពដែលមានភាពស៊ីចង្វាក់ ជាមួយអង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រតិបត្តិករនានា ដើម្បីដាក់ជូនគណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាលពិនិត្យសម្រេច។
- សហការប្រមូល និងវិភាគព័ត៌មាននានាសំដៅក្តាប់ឱ្យជាប់នូវស្មារតី សតិអារម្មណ៍ គោលជំហរ និងសំណូមពររបស់កម្មករនិយោជិត និយោជក សហជីព និងអង្គការវិជ្ជាជីវៈ ដើម្បីធ្វើជាមូលដ្ឋានក្នុងការកសាងកម្មវិធីនយោបាយរបស់គណបក្ស និងឯកសារឃោសនាអប់រំអូសទាញកម្មករនិយោជិត និងនិយោជកឱ្យបន្តចូលរួមគាំទ្រ និងបោះឆ្នោតជូនគណបក្ស។

- សម្របសម្រួលរៀបចំវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាបំប៉នសមត្ថភាពមន្ត្រីគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រតិបត្តិករនានាឱ្យមានសិល្បៈក្នុងការពន្យល់បកស្រាយអំពីសិទ្ធិ និងអត្ថប្រយោជន៍ ដែលគណបក្សបាននិងកំពុងខិតខំការពារ និងផ្ដល់ជូនដល់កម្មករនិយោជិត និយោជក សហជីព និងអង្គការវិជ្ជាជីវៈ។
- ក្រើនរំឭក តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់អង្គការចាត់តាំងគណបក្ស គ្រប់ថ្នាក់ គ្រប់ផ្នែក និងប្រតិបត្តិករនានា លើការងារគ្រប់គ្រង និងពង្រឹងសតិអារម្មណ៍កម្មករ និយោជិត និយោជក សហជីព និងអង្គការវិជ្ជាជីវៈ។
- ណែនាំចាត់តាំង និងផ្សារភ្ជាប់ជាមួយកម្មករនិយោជិត តាមរោងចក្រ សហគ្រាស និងតាមលំនៅដ្ឋាន របស់កម្មករ និយោជិត។
- សហការជាមួយបណ្ដាសហជីព សមាគមនិយោជក និងអង្គការវិជ្ជាជីវៈនានា ក្នុងការកៀរគរធនធាន នានាសម្រាប់បម្រើឱ្យការអនុវត្តផែនការសកម្មភាពរបស់គណៈចលនាសហជីព។
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនគណៈចលនាមហាជន។
- បំពេញភារកិច្ចផ្សេងទៀតដែលគណៈចលនាមហាជនប្រគល់ជូន។

**ប្រការ៣** ៖ គណៈចលនាសហជីព មានរបៀបរបបធ្វើការងារតាមគោលការណ៍សមូហភាពដឹកនាំបុគ្គលទទួលខុសត្រូវ ដោយមានរបបប្រជុំសាមញ្ញមួយខែម្ដង និងប្រជុំវិសាមញ្ញតាមការចាំបាច់ និងតាមការកោះប្រជុំរបស់ប្រធាន។ ប្រធានទទួលខុសត្រូវរួមរាល់ការងាររបស់គណៈចលនាសហជីព និងអាចប្រគល់ភារកិច្ចជូនអនុប្រធានឱ្យទទួលបន្ទុកការងារមួយចំនួនតាមការចាំបាច់។

**ប្រការ៤** ៖ គណៈចលនាសហជីពមានរចនាសម្ព័ន្ធនៅថ្នាក់ជាតិ រាជធានី ខេត្ត និងមានលេខាធិការដ្ឋានមួយជាសេនាធិការ។ គណៈចលនាសហជីពរាជធានី ខេត្ត និងលេខាធិការដ្ឋាន ដឹកនាំដោយប្រធាន០១រូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។

**ប្រការ៥** ៖ លេខាធិការដ្ឋាននៃគណៈចលនាសហជីព មានភារកិច្ចដូចខាងក្រោម៖

- ទទួលបែងចែក គ្រប់គ្រង និងរក្សាទុកឯកសារនានារបស់គណៈចលនាសហជីព គណៈជំនាញនានារបស់គណៈចលនាមហាជន និងស្ថាប័ននានាជុំវិញគណបក្ស។
- រៀបចំសេចក្ដីព្រាងផែនការរួម ផែនការសកម្មភាព កម្រងឯកសារ ស្ថិតិនានាដើម្បីដាក់ជូនគណៈចលនាសហជីពពិនិត្យសម្រេច។
- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារនានាដែលពាក់ព័ន្ធការងារកម្មករនិយោជិត សហជីព និយោជក និងអង្គការវិជ្ជាជីវៈជូនគណៈចលនាសហជីពពិនិត្យសម្រេច។
- ទំនាក់ទំនងផ្ដល់ព័ត៌មានជាមួយអគ្គលេខាធិការដ្ឋានរបស់គណៈចលនាមហាជន។
- រៀបចំកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងការងារពិធីការរបស់គណៈចលនាសហជីព។
- ធ្វើកំណត់ហេតុ ឬរបាយការណ៍ប្រជុំ សិក្ខាសាលា និងសន្និបាតរបស់គណចលនាសហជីព។

- រៀបចំរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំរបស់គណៈចលនាសហជីពរាជធានី ខេត្ត និងប្រតិបត្តិករនានា ជូនប្រធានគណៈចលនាសហជីពពិនិត្យសម្រេច ដើម្បីផ្ញើជូនគណៈចលនាមហាជន។
- រៀបចំផែនការថវិកា និងគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់គណៈចលនាសហជីព។
- បំពេញភារកិច្ចផ្សេងទៀតដែលគណៈចលនាសហជីពប្រគល់ជូន។

**ប្រការ៦** ៖ ដើម្បីបំពេញភារកិច្ចដូចមានចែងក្នុងប្រការ៥ខាងលើនេះឱ្យមានប្រសិទ្ធភាព លេខាធិការដ្ឋាននៃគណៈចលនាសហជីព ត្រូវបានចែកចេញជា៤ផ្នែក ដូចខាងក្រោម៖

១. ផ្នែកគ្រប់គ្រងសហជីព

២. ផ្នែកគ្រប់គ្រងនិយោជក និងអង្គការវិជ្ជាជីវៈ

៣. ផ្នែកគោលនយោបាយ

៤. ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

សមាសភាព និងរបៀបរបបការងាររបស់ផ្នែកនីមួយៗ នៃលេខាធិការដ្ឋានគណៈចលនាសហជីព ត្រូវសម្រេចដោយប្រធានគណៈចលនាមហាជន។

**ប្រការ៧** ៖ ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាលគណបក្ស ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈចលនាសហជីព ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ. គណៈអចិន្ត្រៃយ៍**

**អនុប្រធាន**

**សាយ ឈុំ**

**ចម្លងជូន៖**

- សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល
- ដូចប្រការ "៧"
- ឯកសារ-កាលប្បវត្តិ